អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ពន្ធអាករលើតម្លៃបន្ថែមលើពាណិជ្ជកម្មតាមអនឡាញ លើកពេលអនុវត្តដល់ខែមេសាវិញ
- ឆ្នាំ២០២២ កម្ពុជាមានបរិយាកាសវិនិយោគអំណោយផលច្រើន
- បញ្ហាតួលេខនាំចេញខុសគ្នា ជាបញ្ហាស្មុគស្មាញសម្រាប់ការរៀបចំគោលនយោបាយជាតិស្តីពីស្វាយចន្ទី
- ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងថៃកើនដល់ ៧,៧៩ប៊ីលានដុល្លារក្នុងឆ្នាំ២០២១
- ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា និង វៀតណាមមានតម្លៃជិត ១០ប៊ីលានដុល្លារ
- កំណើនប្រាក់បញ្ញើនៅក្នុងធនាគាររបស់អតិថិជនបានធ្លាក់ចុះនៅក្នុងឆ្នាំ២០២១
- ដោយសារតែតម្លៃប្រេងឡើងថ្លៃ រដ្ឋាភិបាលជប៉ុនសម្រេចផ្តល់ឧបត្ថម្ភធនដល់អ្នកលក់ប្រេង
- វៀតណាម នឹងមានតម្រូវការម្រេចពីកម្ពុជាច្រើន
- រុស្ស៊ី ចង់ពង្រឹងទំនាក់ទំនងជាមួយប្រទេសអាស៊ាន
- ការតម្លើងអត្រាការប្រាក់របស់ធនាគារសហព័ន្ធអាមេរិក នឹងអាចធ្វើឱ្យវិបត្តិបំណុលសកលកាន់តែធ្ងន់ធ្ងរ
- លោក ចូ បៃឌិន៖ មិនទាន់ដល់ពេលដែលត្រូវដកការនាំងពន្ធគយពីទំនិញចិនឡើយ
- អាមេរិក និងអង់គ្លេស ផ្តើមកិច្ចពិភាក្សាដោះស្រាយជម្លោះពាណិជ្ជកម្មលើពន្ធដែកថែប និងអាលុយមីញ៉ូម


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី១ ខែកុម្ភៈ ឆ្នាំ២០២២ លេខ ៖ ១០៤

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ពន្ធអាករលើតម្លៃបន្ថែមលើពាណិជ្ជកម្មតាមអនឡាញ លើកពេលអនុវត្តដល់ខែមេសា




*ដោយ ៖ ខេមបូណ្ឌមីស*

អគ្គនាយកដ្ឋានពន្ធដារនឹងចាប់អនុវត្តយកពន្ធអាករលើតម្លៃបន្ថែម សម្រាប់ក្រុមហ៊ុន សហគ្រាស និងនិវាសនបុគ្គលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។ តាមគម្រោង យន្តការយកពន្ធអាករលើតម្លៃបន្ថែមនេះ អគ្គនាយកដ្ឋានពន្ធដារត្រូវចាប់អនុវត្តពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ តទៅ តែត្រូវបានពន្យារពេលអនុវត្តរហូតដល់ខែមេសា។ ការពន្យារពេលនេះគឺដើម្បីទុកពេលឱ្យក្រុមហ៊ុន សហគ្រាស និងអាជីវករលើវិស័យនេះ បានសិក្សាពីយន្តការនេះឱ្យបានស៊ីជម្រៅ និងច្បាស់លាស់បន្ថែមទៀត។

គោលបំណងនៃការដាក់ឱ្យអនុវត្តកម្មវិធីយកពន្ធអាករលើតម្លៃបន្ថែមខាងលើ គឺដើម្បីរួមចំណែកកៀរគរចំណូលពន្ធជូនរដ្ឋបន្ថែម ក្រោយពីសង្កេតឃើញថាក្រុមហ៊ុន សហគ្រាស និងអាជីវករតាមប្រព័ន្ធអេឡិចត្រូនិកមានការកើនឡើងនាពេលបច្ចុប្បន្ន គឺបន្ទាប់ពីមានការរីកចម្រើនខ្លាំងនៃប្រព័ន្ធបច្ចេកវិទ្យានៅសតវត្សរ៍ទី២១ នេះ។ ក្នុងអំឡុងនៃការពន្យារពេលនេះ អគ្គនាយកដ្ឋានពន្ធដារ ស្នើក្រុមហ៊ុន សហគ្រាស ឬអាជីវករតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានផលរបរចាប់ពី២៥០ លានរៀល រួសរាន់មកចុះបញ្ជីអាករលើតម្លៃបន្ថែមឱ្យបានមុនថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារ ក៏ព្រមានចាត់វិធានការតាមផ្លូវច្បាប់ និងផាកពិន័យចំពោះក្រុមហ៊ុន សហគ្រាស និងបុគ្គលណា ដែលធ្វើអាជីវកម្មដោយគ្មានលិខិតអនុញ្ញាតផងដែរ។

ពាក់ព័ន្ធការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ក្រសួងពាណិជ្ជកម្មកម្ពុជាបានសម្រេចពន្យារពេលចុះបញ្ជី និងផាកពិន័យសម្រាប់សហគ្រាសឯកបុគ្គលនីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសរហូតដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ផងដែរ។ ព្រោះក្រសួងសង្កេតឃើញមានក្រុមហ៊ុន សហគ្រាស និងអាជីវករតាមប្រព័ន្ធអេឡិចត្រូនិកមួយចំនួន កំពុងរៀបចំឯកសារដើម្បីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២៥ខែមករា ឆ្នាំ២០២២។*

### NGO១០០ស្ថាប័នស្នើរាជរដ្ឋាភិបាលដំឡើងពន្ធថ្នាំជក់




*ដោយ ៖ Postkhmer*

អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើវិស័យសុខភាពប្រមាណ ១០០ ស្ថាប័ន បានស្នើសុំរាជរដ្ឋាភិបាលដំឡើងពន្ធថ្នាំជក់។ ថ្នាំជក់ ជាផលិតផលដែលសម្លាប់មនុស្សប្រមាណ៥០% នៃអ្នកដែលប្រើប្រាស់វា។ រៀងរាល់ឆ្នាំនៅទូទាំងសកលលោកមនុស្សប្រមាណ ៧ លាននាក់បានស្លាប់ដោយការប្រើប្រាស់ថ្នាំជក់ផ្ទាល់ និងប្រមាណ ១ លាននាក់ បានស្លាប់ដោយសារតែការស្រូបផ្សែងថ្នាំជក់ពីគេ។ ក្នុងចំណោមអ្នកស្លាប់ទាំងនោះមានប្រជាពលរដ្ឋកម្ពុជាប្រមាណ ១៥ ០០០ នាក់ផងដែរ។

នាយកប្រតិបត្តិអង្គការចលនាដើម្បីសុខភាពកម្ពុជា បានលើកឡើងថា ប្រជាពលរដ្ឋកម្ពុជា ៩៤%បានគាំទ្រវិធានការដំឡើងពន្ធថ្នាំជក់។ ការដំឡើងពន្ធថ្នាំជក់ជាវិធានការដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយការឈឺ ស្លាប់ ពិការភាព ព្រមទាំងបង្កើនចំណូលពន្ធផងដែរ ប៉ុន្តែការដំឡើងពន្ធថ្នាំជក់នេះ តែងជួបប្រទះនូវឧបសគ្គជាច្រើន។ ក្រុមហ៊ុនថ្នាំជក់បានដឹងច្បាស់ថា ការដំឡើងពន្ធថ្នាំជក់នាំឱ្យតម្លៃបារីឡើងថ្លៃ អាចកាត់បន្ថយការប្រើប្រាស់ ដូចនេះក្រុមហ៊ុនថ្នាំជក់បានប្រើប្រាស់គ្រប់មធ្យោបាយដើម្បីរារាំងការដំឡើងពន្ធថ្នាំជក់។ ល្បិចកលរបស់ពួកគេ គឺផ្សព្វផ្សាយព័ត៌មានមិនពិតដែលថា ដំឡើងពន្ធថ្នាំជក់ប៉ះពាល់ដល់អ្នកជក់បារីដែលមានប្រាក់ចំណូលទាប និងនាំទៅរកការគេចពន្ធ។

ប្រទេសជាច្រើនលើពិភពលោកបានបញ្ជាក់ច្បាស់ថា ការដំឡើងពន្ធថ្នាំជក់ គឺជាគោលនយោបាយឈ្នះ-ឈ្នះ សម្រាប់រដ្ឋាភិបាល។ ឈ្នះទី ១ គឺរដ្ឋាភិបាលនឹងទទួលបានប្រាក់ចំណូលពន្ធបន្ថែម។ រីឯឈ្នះទៅ ២ គឺវិធានការនេះល្អ សម្រាប់សុខភាពសាធារណៈ ព្រោះអ្នកជក់បារីជក់តិចជាងមុន ឬឈប់ជក់តែម្តង ខណៈយុវជនមិនអាចទិញបារីបាន។

អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានថ្លែងថា ការដំឡើងពន្ធនេះ ជាផែនការស្នូលក៏ប៉ុន្តែគឺត្រូវថ្លឹងថ្លែងទៅលើប្រសិទ្ធភាពនៃការអនុវត្ត។ ក្នុងដំណាក់កាលនេះ ការដំឡើងពន្ធមិនអាចធ្វើឡើងឱ្យហួសពីសមត្ថភាពបាននោះទេ ព្រោះការដំឡើងពន្ធឱ្យខ្ពស់ អាចនឹងមានអំពើល្មើស មិនត្រឹមតែមានការរត់ពន្ធខុសច្បាប់ទេ គឺមានទំនិញក្លែងក្លាយ។ តាមផែនការរបស់រដ្ឋាភិបាល គឺមិនអាចដំឡើងពន្ធភ្លាមឱ្យដល់ ៧៥%ដូចអ្វីដែលបានលើកឡើងនោះទេ គឺអាស្រ័យទៅលើស្ថានភាព និងបរិបទនៃការរីកចម្រើនរបស់ប្រទេស។ បច្ចុប្បន្នពន្ធថ្នាំជក់នៅប្រទេសកម្ពុជានៅមានអត្រា ២៥% នៃតម្លៃលក់រាយ សម្រាប់បារីផលិតក្នុងស្រុក និង ៣១% សម្រាប់បារីនាំចូល ដែលអត្រានេះ នៅមានកម្រិតទាបនៅឡើយបើធៀបជាមួយអត្រាពន្ធថ្នាំជក់នៃប្រទេសអាស៊ានផ្សេងៗទៀត៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ postkhmer ចេញផ្សាយថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២។*

## CSXបំបែកកំណត់ត្រាការជួញដូរភាគហ៊ុនឆ្នាំ២០២១



*ដោយ ខេមបូណូមីស(អគ្គនាយកផ្សារមូលបត្រកម្ពុជា CSX)*

នៅឆ្នាំ២០២១កន្លងទៅនេះ បរិមាណជួញដូរភាគហ៊ុនប្រចាំថ្ងៃគិតជាមធ្យមមានជាង ២៣ម៉ឺនភាគហ៊ុន និងតម្លៃជួញដូរភាគហ៊ុនមានជាង ២៥ម៉ឺនដុល្លារ បើធៀបនឹងឆ្នាំ២០២០ ទំហំជួញដូរភាគហ៊ុនមានការកើនឡើងរហូតប្រមាណ ៤០០% និងតម្លៃជួញដូរវិញកើនឡើងដល់ទៅ ១២៧%។

ជុំវិញនឹងកំណើននៃការជួញដូរភាគហ៊ុនក្នុងទីផ្សារមូលបត្រនេះដែរ ត្រូវបានប្រតិកូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកផ្សារមូលបត្រកម្ពុជា បានគូសបញ្ជាក់ថា ពិតមែនតែមានការរំខានច្រើនពីកូវីដ១៩ ហើយក្រុមហ៊ុនចុះបញ្ជីជួបឧបសគ្គច្រើនមិនអាចមកចុះបញ្ជីបាន តាមការគ្រោងទុកក្តី ប៉ុន្តែសកម្មភាពលើទីផ្សារហាក់មានការកើនឡើងគួរឱ្យកត់សម្គាល់។ មានកត្តាជាច្រើនដែលធ្វើឱ្យសកម្មភាពលើទីផ្សារមានការកើនឡើង ក្នុងនោះកូវីដ១៩ ក៏ជាឱកាសដល់វិនិយោគិនមានពេលវេលាច្រើនក្នុងការស្វែងយល់ពីវិស័យមូលបត្រ។ ម្យ៉ាងវិញទៀត កូវីដ១៩ បានធ្វើឱ្យតម្លៃភាគហ៊ុនមួយចំនួនធំធ្លាក់ចុះដូច្នេះអ្នកវិនិយោគក៏មើលឃើញឱកាស ក្រោយស្ថានភាពកូវីដបានធូរស្បើយឡើងវិញ ទើបវិស័យមូលបត្រហាក់មានការកើនឡើង ទាំងការបើកគណនីជួញដូរ និងការដាក់បញ្ជាទិញ-លក់ភាគហ៊ុន។ ក្រុមហ៊ុនថ្មីៗចុះបញ្ជីនឹងកើនឡើងថែមទៀត ទំហំជួញដូរនឹងបន្តកើនឡើងដែរ នៅឆ្នាំបន្ទាប់ ខណៈឆ្នាំ២០២១ ទំហំជួញដូរប្រចាំថ្ងៃកើនឡើងដល់ជាង២៥ម៉ឺនដុល្លារ ជាមធ្យម។ បើសិនជាស្ថានភាពកូវីដ១៩ បានធូរស្បើយ ផ្សារមូលបត្រនឹងបន្តកើនឡើង ក្នុងរយៈពេលប៉ុន្មានឆ្នាំទៅមុខទៀត ដោយលោករំពឹងថា នៅឆ្នាំ២០២២នេះទំហំជួញដូរប្រចាំថ្ងៃនឹងមានប្រមាណ ៣០ម៉ឺនដុល្លារ។

រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងដំណើរការទីផ្សារមូលបត្របំណុលរបស់រដ្ឋ ដែលគ្រប់បណ្តាអង្គភាពពាក់ព័ន្ធរបស់ក្រសួង កំពុងធ្វើការយ៉ាងមមាញឹកលើរឿងនេះ ជាមួយភាគីពាក់ព័ន្ធ រួមមាន និយ័តករមូលបត្រកម្ពុជា ធនាគារជាតិនៃកម្ពុជា និងផ្សារមូលបត្រកម្ពុជា ជាដើម ដើម្បីធានាថា នឹងអាចបោះផ្សាយរមូលបត្រក្នុងឆ្នាំ២០២២។ តែយ៉ាងណា ភាពមិនប្រាកដប្រជានៃកូវីដ១៩ ពិសេសវត្តមានវីរុសអូមីក្រុង និងការសម្រេចចិត្តរបស់ម្ចាស់ភាគហ៊ុន អាចនឹងធ្វើឱ្យវិស័យផ្សារមូលបត្រកម្ពុជា មានការប្រែប្រួល៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២១ ខែមករា ឆ្នាំ២០២២។*

## ឆ្នាំ២០២២ កម្ពុជាមានបរិយាកាសវិនិយោគអំណោយផលច្រើន



*ដោយ ខេមបូណ្ឌមីស*

ច្បាប់វិនិយោគថ្មី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគីបានធ្វើឱ្យប្រសើរឡើងនូវឱកាសវិនិយោគ និងការធ្វើធុរកិច្ចនៅកម្ពុជា។ គិតចាប់តាំងពីថ្ងៃទី១ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តគម្រោងវិនិយោគថ្មីៗចំនួន ២២គម្រោង ជាមួយទុនសរុបជិត២ពាន់លានដុល្លារអាមេរិក និងបានផ្តល់ការងារជូនប្រជាជនជាង២ម៉ឺនកន្លែង ដែលមានការកើនឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ជាក់ស្តែង នៅពេញមួយខែមករា ឆ្នាំ២០២១ CDC បានអនុម័តលើគម្រោងវិនិយោគសរុបតែ១១គម្រោងប៉ុណ្ណោះ។

អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា សង្កេតឃើញថា ការវិនិយោគលើគម្រោងថ្មីៗនៅកម្ពុជា មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់នៅដើមឆ្នាំ២០២២នេះ។ កត្តាដែលជំរុញឱ្យការវិនិយោគមានកំណើននេះ គឺដោយសារកម្ពុជា បានកែប្រែលក្ខខណ្ឌវិនិយោគល្អប្រសើរជាងមុន តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីការវិនិយោគនៅកម្ពុជា។ ម្យ៉ាងទៀត កម្ពុជាមានកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ ថ្នាក់

តំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ហើយកម្ពុជាក៏ស្ថិតនៅក្រោមកម្មវិធីអនុគ្រោះពន្ធ GSP ពីប្រទេសមួយចំនួនទៀតផងដែរ។ តាមរយៈកិច្ចព្រមព្រៀងខាងលើ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង ដែលគ្រោងចូលជាធរមានក្នុងពេលឆាប់ៗ និងកម្ពុជាធ្វើជាប្រធានអាស៊ាន និងអាស៊ានបូកនៅឆ្នាំនេះ វានឹងជួយទាក់ទាញវិនិយោគិនបរទេសឱ្យមកបោះទុនវិនិយោគនៅកម្ពុជាកាន់តែច្រើនថែមទៀត។

អ្នកស្រាវជ្រាវសេដ្ឋកិច្ច និងជាប្រធានមជ្ឈមណ្ឌលសិក្សាចិននៃរាជបណ្ឌិតសភាកម្ពុជា វាយតម្លៃថា វិនិយោគិនជាតិ និងអន្តរជាតិ នឹងមានការកើនឡើងនៅឆ្នាំ២០២២នេះ។ ការវាយតម្លៃបែបនេះ ដោយលោកផ្អែកលើការជួយសម្រួលលក្ខខណ្ឌវិនិយោគពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី ដែលកម្ពុជាសម្រេចបាន។

បើយើងក្រឡេកទៅមើលនៅឆ្នាំ២០២១ កន្លងទៅ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តគម្រោងសរុបចំនួន១៦១គម្រោង ដោយមានទុនវិនិយោគជិត៤ពាន់លានដុល្លារ និងបានបង្កើតការងារដល់ប្រជាជនជាង១០ម៉ឺនកន្លែង៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២។*

## បញ្ហាតួលេខនាំចេញខុសគ្នា ជាបញ្ហាស្មុគស្មាញសម្រាប់ការរៀបចំគោលនយោបាយជាតិស្ដីពីស្វាយចន្ទី



*ដោយ ខេមបូណ្ឌមីស*

ក្រសួងពាណិជ្ជកម្ម បាននិងកំពុងរៀបចំនូវគោលនយោបាយជាតិស្ដីពី ស្វាយចន្ទី។ ថ្មីៗនេះ ក្រសួងពាណិជ្ជកម្មបានបើកកិច្ចប្រជុំជាមួយបណ្ដាអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាងគោលនយោបាយជាតិស្ដីពី ស្វាយចន្ទី ដោយរំពឹងថានឹងដាក់ជូនទៅកាន់គណៈរដ្ឋមន្ត្រីពិនិត្យពិភាក្សាបន្ត ឆាប់ៗតាមដែលអាចធ្វើបាន ក្នុងគោលបំណងទាក់ទាញអ្នកវិនិយោគ និងជំរុញការនាំចេញស្វាយចន្ទី។

សមាគមស្វាយចន្ទីកម្ពុជាអះអាងថា ការរៀបចំគោលនយោបាយជាតិស្ដីពីស្វាយចន្ទី ពិតជាមានសារៈសំខាន់ណាស់ ពិសេសសម្រាប់អ្នកដាំដុះ អ្នកវិនិយោគ ក៏ដូចជា សមាគមស្វាយចន្ទីនៅកម្ពុជាផងដែរ។ ក៏ប៉ុន្តែ អ្វីដែលជាបញ្ហានៅក្នុងការរៀបចំគោលនយោបាយជាតិនេះ គឺការកំណត់ទិន្នន័យនៃការនាំចេញគ្រាប់ស្វាយចន្ទី ដោយតួលេខផ្ដល់ឱ្យកន្លងមក ពីខាងគយកម្ពុជា និងគយវៀតណាម មានភាពខុសគ្នា ដែលវាពិបាកក្នុងការកំណត់ពីចំនួនជាក់លាក់ ដើម្បីចងក្រងជាគោលនយោបាយ។ កន្លងមក ភាគីពាក់ព័ន្ធបានបើកកិច្ចប្រជុំច្រើនលើកច្រើនសាររួចមកហើយ ទាក់ទងនឹងគោលនយោបាយជាតិស្ដីពីស្វាយចន្ទីនេះ។ គ្រាប់ស្វាយចន្ទីកម្ពុជា ស្ទើរតែ៩០%ទៅហើយ ត្រូវបាននាំចេញទៅប្រទេសវៀតណាម តែភាគច្រើននាំចេញទៅតាមច្រករបៀង ដូច្នេះ ទើបធ្វើឱ្យការកត់ត្រាទិន្នន័យនាំចេញ-ចូល ពីកម្ពុជា និងវៀតណាម មិនដូចគ្នា។ កាលណាការកំណត់ទិន្នន័យនាំចេញគ្រាប់ស្វាយចន្ទីមិនបានជាក់លាក់ សេចក្ដីព្រាងនេះ នឹងមិនអាចដាក់ជូនថ្នាក់គណៈរដ្ឋមន្ត្រីដើម្បីសម្រេចបានឡើយ។

កសិករម្នាក់ដាំស្វាយចន្ទី នៅខេត្តកំពង់ធំ បានប្រាប់ថា ការដាំស្វាយចន្ទីមិនសូវកាក់កបទេ ព្រោះតម្លៃលក់បានទាប តែថ្លៃជី និងថ្នាំកសិកម្ម កាន់តែមានតម្លៃខ្ពស់

បច្ចុប្បន្ន គ្រាប់ស្វាយចន្ទី អាចលក់បានក្នុងតម្លៃ៥ពាន់រៀល ប៉ុណ្ណោះ ក្នុង១គីឡូក្រាម ដែលកាលពីមុនអាចលក់បាន ៧ពាន់រៀល ទៅ៨ពាន់រៀល ក្នុង១គីឡូក្រាម។ តម្លៃប្រែប្រួលទៅតាមឈ្មួញកណ្ដាល ទោះចង់ ឬមិនចង់កសិករក៏ត្រូវតែលក់ឱ្យឈ្មួញទាំងនោះ ព្រោះមានតែវៀតណាមទេ ដែលប្រមូលទិញគ្រាប់ស្វាយចន្ទី។

បច្ចុប្បន្ន គ្រាប់ស្វាយចន្ទីភាគច្រើនរបស់កម្ពុជាមិនទាន់កែច្នៃដើម្បីនាំចេញផ្ទាល់ក៏ដោយ ប៉ុន្តែគ្រាប់ស្វាយចន្ទីទាំងនោះ នៅតែមានទីផ្សារច្រើនគួរសម ដូចជា ទីផ្សារថៃ ឥណ្ឌា ចិន និងវៀតណាមជាដើម។ កម្ពុជាក៏មាននាំចេញគ្រាប់ស្វាយចន្ទីកែច្នៃមួយចំនួនទៅប្រទេសជប៉ុនផងដែរ។ ក្នុងឆ្នាំ២០២១ កម្ពុជា បាននាំចេញគ្រាប់ស្វាយចន្ទី សរុបជាង៩៣ម៉ឺនតោន ទៅកាន់ទីផ្សារសំខាន់ៗ ដូចជា វៀតណាម ថៃ ជប៉ុន ចិន ឥណ្ឌា និងទីផ្សារដទៃទៀត។ ក្នុងនោះ គ្រាប់ស្វាយចន្ទីប្រមាណ៩២ម៉ឺនតោន ទៅហើយត្រូវបាននាំទៅទីផ្សារវៀតណាម។ កន្លងមកតម្លៃគ្រាប់ស្វាយចន្ទី អាចលក់បានតម្លៃ ១ ៤០០ដុល្លារ ទៅ១ ៦០០ដុល្លារ ក្នុង១តោន៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណ្ឌីសចេញផ្សាយថ្ងៃទី២៨ខែមករា ឆ្នាំ២០២២។*

## តារាងប្រចាំសប្ដាហ៍

### តារាងទី១៖កំណើននៃការនាំចេញទំនិញរយៈពេល១១ខែដំបូង ក្នុងឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖នៅក្នុងរយៈពេល១១ខែ ឆ្នាំ២០២១ ការនាំចេញទំនិញវាយនភ័ណ្ឌ មានកំណើនប្រមាណជា ១៣,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។

ដោយឡែក នៅក្នុងរយៈពេល១១ខែ ឆ្នាំ២០២១ ការនាំចេញកង់មានកំណើនប្រមាណជា ១៩,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

ស្របពេលនោះដែរ ការនាំចេញទំនិញផ្សេងៗ ក៏មានកំណើនខ្លាំងប្រមាណជា៥៣,១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។

ទោះបីយ៉ាងណាក៏ដោយ ការនាំចេញអង្ករនៅក្នុងរយៈពេល១១ខែឆ្នាំ២០២១ ក៏មានការធ្លាក់ចុះប្រមាណជា ១០,៧%ផងដែរ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០២០។

ដោយ៖ មិត្ត ចន្ទី




*ប្រភព៖និន្នាការសេដ្ឋកិច្ចសង្គម៖ របាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០២១*

### តារាងទី២៖ ចំណែកទីផ្សារអន្តរជាតិសម្រាប់ទំនិញនាំចេញកម្ពុជាក្នុងរយៈពេល១១ខែ ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ ក្នុងរយៈពេល១១ខែ ឆ្នាំ២០២១ ការនាំចេញទំនិញកម្ពុជាទៅកាន់ទីផ្សារបរទេស ដែលក្នុងនោះ អាមេរិកមានចំណែកទីផ្សារធំជាងគេរហូតដល់ ៤២,៨% នៃការនាំចេញសរុប ។ បន្ទាប់មក សហគមន៍អឺរ៉ុបឈរនៅលេខរៀងទីពីរ ដែលមានចំណែកទីផ្សារប្រមាណជា១៨,៥% នៃការនាំចេញសរុបរបស់កម្ពុជា។

ទន្ទឹមនឹងនោះដែរ ការនាំចេញទៅកាន់បណ្តាប្រទេសផ្សេងៗមានចំណែកទីផ្សារនាំចេញប្រមាណជា១៣% នៃការនាំចេញសរុប។

ស្របពេលនោះដែរ ចិនមានចំណែកទីផ្សារប្រមាណជា ៨,៨% ជប៉ុនមាន៦,៤% បណ្តាប្រទេសអាស៊ានមាន ៦,៣% និងអង់គ្លេសមានចំណែកទីផ្សារ ៤,២% ៕

ដោយ មិត្ត ចន្ទី




*ប្រភព៖និន្នាការសេដ្ឋកិច្ចសង្គម៖ របាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងថៃកើនដល់ ៧,៧៩ប៊ីលានដុល្លារក្នុងឆ្នាំ២០២១



*ប្រភព៖ខ្មែរថាម ២០២២*

យោងតាមក្រសួងពាណិជ្ជកម្មរបស់ថៃបានបង្ហាញថា ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងថៃមានតម្លៃ ៧,៩៧ ប៊ីលានដុល្លារក្នុងឆ្នាំ២០២១ កើនឡើង ១០,២៦%បើធៀបនឹងឆ្នាំ២០២០ ។

ក្នុងឆ្នាំ២០២១ កម្ពុជាបាននាំចូលទំនិញពីប្រទេសជិតខាងមានតម្លៃជាង ៧ប៊ីលានដុល្លារ កើនឡើង ១៦,៣៧% ធៀបនឹងឆ្នាំ២០២០ ។ ការនាំចូលផលិតផលពីប្រទេសថៃរួមមាន ត្រី សាច់ បន្លែ រថយន្ត ជីសីរាង្គ គ្រឿងឧបភោគបរិភោគ និងសម្ភារសំណង់។ ចំណែកឯកម្ពុជាបាននាំចេញផលិតផលសំខាន់ៗទៅប្រទេសថៃរួមមាន វាយនភណ្ឌ ផលិតផលកសិកម្មត្បូង វត្ថុធាតុដើម និងផលិតផលផ្សេងៗទៀត មានតម្លៃ ៨៩៤ លានដុល្លារ ធ្លាក់ចុះ ២២,១០ % ។

លោក លឹម ហេង អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានលើកឡើងថា៖ ដើម្បីជំរុញការនាំចេញកសិផលទៅកាន់ទីផ្សារ ការងារទាក់ទងនឹងអនាម័យ និងភូតគាមអនាម័យ ចាំបាច់ត្រូវកែលម្អ ជាពិសេសការវិនិយោគពីវិស័យឯកជន ក្នុងការកសាងគ្រឿងបរិក្ខារជាឃ្លាំងត្រជាក់នៅតាមព្រំដែនសម្រាប់ផលិតផលកសិកម្មដើម្បីអនុវត្តតាមស្តង់ដារអនាម័យ និងភូតគាមអនាម័យ។ ពាណិជ្ជកម្មរវាងកម្ពុជា និងថៃបានកើនឡើងយ៉ាងខ្លាំងរួមទាំងលំហូរទំនិញរវាងប្រទេសទាំងពីរបន្ទាប់ពីសកម្មភាពពាណិជ្ជកម្មរវាងប្រទេសទាំងពីរបានដំណើរការឡើងវិញពីជំងឺរាតត្បាតកូវិដ-១៩ដែលបានដាក់វិធានការតឹងរ៉ឹងលើការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន។ ប្រទេសទាំងពីរបានដាក់ក្តីសង្ឃឹមខ្ពស់ក្នុងការបន្តជំរុញពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ថៃ ឱ្យឡើងដល់ ១៥ប៊ីលានដុល្លារនៅឆ្នាំ ២០២៣៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ ខ្មែរថាម ចេញផ្សាយថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២២*

### ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា និងវៀតណាមមានតម្លៃជិត ១០ប៊ីលានដុល្លារ




*ប្រភព៖ខ្មែរថាម ២០២២*

តាមរយៈការបំពេញទស្សនៈកិច្ចរបស់រដ្ឋមន្ត្រីការបរទេសវៀតណាម មកកាន់ប្រទេសកម្ពុជាថ្មីៗនេះគឺ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃកម្ពុជាបានជួបពិភាក្សាការងារជាមួយលោក Bui Thanh Son រដ្ឋមន្ត្រីការបរទេសវៀតណាម លើវិស័យពាណិជ្ជកម្ម និងទេសចរណ៍ ដោយភាគីទាំងពីរបានប្តេជ្ញាបង្កើនទំហំពាណិជ្ជកម្មឱ្យលើសពី១០ប៊ីលានដុល្លារក្នុងឆ្នាំ២០២២។ ក្នុងជំនួបនោះបានបញ្ជាក់ផងដែរថា៖ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងវៀតណាម បានកើនឡើងដល់ជិត ១០ ប៊ីលានដុល្លារកាលពីឆ្នាំមុន ហើយប្រទេសទាំងពីរនឹងបន្តពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច និងធ្វើការរួមគ្នាដើម្បីបង្កើនទំហំពាណិជ្ជកម្មនៅឆ្នាំ២០២២ បន្ថែមទៀត។ ទន្ទឹមនឹងនេះភាគីប្រទេសទាំងពីររំពឹងថានឹងពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យកសិកម្ម និងឧស្សាហកម្ម រួមទាំងការបើកជើងហោះហើរត្រង់រវាងវៀតណាម និងកម្ពុជាឡើងវិញដើម្បីផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរ។

ស្របពេលជាមួយគ្នានេះ ភាគីទាំងពីរបន្តធ្វើការលើការវិនិយោគទេសចរណ៍ ដើម្បីធ្វើឱ្យសេដ្ឋកិច្ចមានទំនាក់ទំនងគ្នាទៅវិញទៅមក និងបានលើកឡើងអំពីផែនការនៃការសាងសង់ផ្លូវរថភ្លើងតភ្ជាប់រវាងកម្ពុជា និងវៀតណាមក្នុងគោលបំណងសម្រួលដល់ការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសទាំងពីរ។

យោងតាមទិន្នន័យពីការិយាល័យពាណិជ្ជកម្មវៀតណាមប្រចាំនៅកម្ពុជា បើទោះជាមានផលប៉ះពាល់ពីជំងឺកូវីដ-១៩ក៏ដោយពាណិជ្ជកម្មសរុបរវាងវៀតណាម និងកម្ពុជាបានឈានដល់ ៩,៣ប៊ីលានដុល្លារក្នុងឆ្នាំ ២០២១ ដែលជាការឈានទៅមុខយ៉ាងខ្លាំងចំនួន៧៥%បើធៀបនឹងឆ្នាំ ២០២០។

ក្នុងឆ្នាំ២០២១ ក្រុមហ៊ុនវៀតណាមបានចាក់បញ្ចូលទឹកប្រាក់ជាង ៨៨,៩លានដុល្លារ ទៅក្នុងគម្រោងថ្មីចំនួន ៤ នៅក្នុងប្រទេសកម្ពុជា ដែលបង្កើនការវិនិយោគសរុបរបស់វៀតណាមដល់ទៅជាង ២,៨៤ ប៊ីលានដុល្លារ ដែលធ្វើឱ្យវៀតណាមក្លាយជាអ្នកវិនិយោគបរទេសធំជាងគេមួយក្នុងចំណោមវិនិយោគិនបរទេសធំជាងគេទាំង៥នៅកម្ពុជា។

ក្នុងចំណោមផលិតផលកម្ពុជានាំចេញទៅវៀតណាមចំនួន១១ប្រភេទមានផលិតផលចំនួន៩ប្រភេទដែលមានកំណើនវិជ្ជមានក្នុងនោះរួមមាន៖ បន្លែ ផ្លែឈើ គ្រាប់ស្វាយចន្ទី កៅស៊ូ និងផលិតផលផ្សេងៗទៀត។ ចំណែកផលិតផលរបស់វៀតណាមចំនួន ២៤ក្រុមក្នុងចំណោម២៩ក្រុមដែលនាំចូលមកកម្ពុជាមានកំណើនវិជ្ជមានរួមមានបន្លែ ដំឡូង ផ្លែឈើ ចំណីសត្វ វត្ថុធាតុដើម ប្រេងឥន្ធនៈ ប្រេង ជី និងផលិតផលផ្សេងៗទៀត។ ប្រទេសវៀតណាម និងកម្ពុជាបានប្រកាសពីប្រាក់ចំណូលនាំចូល និងនាំចេញសរុបជាង ៥,៣២ ប៊ីលានដុល្លារក្នុងឆ្នាំ ២០២០ ដែលកើនឡើងបន្តិចក្នុងចំនួន ០,៨៤ %បើធៀបនឹងឆ្នាំ ២០១៩៕ *ដោយ សេន ចន្ទូ*

*ប្រភព៖ខ្មែរថាម ចេញផ្សាយថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២*

## **ការលក់រថយន្តរបស់ថៃធ្លាក់ចុះ១៧,២%នៅខែធ្នូ ឆ្នាំ ២០២១**

នៅក្នុងខែធ្នូ ឆ្នាំ២០២១ សហព័ន្ធឧស្សាហកម្មថៃ (FTI)លក់រថយន្តបានចំនួន ៨៦ ១៤៥គ្រឿង ធ្លាក់ចុះ

១៧,២% ធៀបនឹងរយៈពេលដូចគ្នានឹងឆ្នាំមុន និងការលក់ប្រចាំឆ្នាំ២០២១ មានចំនួន៧៥៩ ១១៩គ្រឿង ធ្លាក់ចុះ ៤,២%។ ការធ្លាក់ចុះនេះបណ្តាលមកពីការផ្ទុះឡើងនៃមេរោគកូវីដ-១៩ និងកង្វះមីក្រូឈីព(Micro chips)។

នៅក្នុងឆ្នាំ២០២២ខាងមុខនេះ (FTI)ព្យាករណ៍ថាការលក់របស់ខ្លួននៅក្នុងស្រុកស្ថិតក្នុងចន្លោះពី ៨០០ ០០០ទៅ ៨៥០ ០០០គ្រឿង ឬកើនឡើងពី ៥,៤% ទៅ ១២% ការកើនឡើងនេះជំរុញមកពីការបន្ធូរបន្ថយការទប់ស្កាត់ការធ្វើដំណើរ និងការស្តារសេដ្ឋកិច្ចឡើងវិញ។ ទន្ទឹមនឹងនេះដែរ ការនាំចេញរថយន្តបានកើនឡើង ៤៨% នៅក្នុងខែធ្នូ ឆ្នាំ២០២១ ធៀបនឹងឆ្នាំមុន ហើយកើនឡើង ៣០,៤% ក្នុងឆ្នាំ២០២១។ សម្រាប់ ២០២២ (FTI )រំពឹងថាការនាំចេញរថយន្តនឹងកើនឡើង ៤,៣% ដែលមានចំនួនរហូតដល់ ១លានគ្រឿង។

*ដោយ មុំ ចិន្តា*

*ប្រភព៖* Thailand Automotive Institute

**តារាងលក់រថយន្តប្រចាំខែរបស់(FTI)ឆ្នាំ២០២១ (គ្រឿង)**




## វៀតណាម នឹងក្លាយជាទីផ្សារនៃម៉ាក្សយីហោផលិតផលប្រណីតៗ




*ដោយ ខេមបុណ្ណមីស*

ប្រទេសវៀតណាមនាពេលបច្ចុប្បន្ននេះ ហាក់មិនសូវជាទីចាប់អារម្មណ៍នៃទីផ្សារទំនិញប្រណីតនោះទេ ប៉ុន្តែប្រទេសនេះ អាចក្លាយជាទីផ្សារដែលផ្តល់ប្រាក់ចំណេញខ្ពស់នាពេលអនាគតដ៏ខ្លីខាងមុខនេះព្រោះអាចបណ្តាលមកពីការកើនឡើងនៃប្រាក់ចំណូលរបស់ប្រជាជនវៀតណាម នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ អ្នកប្រើប្រាស់ដែលមានប្រាក់ចំណូលខ្ពស់ គឺជាឆ្អឹងខ្នងដ៏សំខាន់នៃការប្រើប្រាស់ទំនិញផលិតផលប្រណិតៗម៉ាកយីហោល្បីៗ។

នៅចន្លោះឆ្នាំ ២០០២ ដល់ឆ្នាំ ២០២០ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់នៅវៀតណាមបានកើនឡើងជិត៣ដង ដោយក្នុងមួយឆ្នាំចំណូលពលរដ្ឋម្នាក់ជាមធ្យមមានប្រមាណ ២៨០០ដុល្លារ។ ធនាគារពិភពលោកក៏ធ្លាប់បានគូសបញ្ជាក់ថា ប្រទេសវៀតណាមអាចក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣៥ ជាមួយនឹងប្រាក់ចំណូលសម្រាប់ពលរដ្ឋម្នាក់អាចរហូតដល់ ៧០០០ដុល្លារក្នុងមួយឆ្នាំ។ បច្ចុប្បន្ននេះ ចំនួនប្រជាជនវណ្ណៈកណ្តាលរបស់វៀតណាមក៏កំពុងកើនឡើងយ៉ាងច្រើនផងដែរ ដោយរំពឹងថា នឹងកើនឡើងដល់ ៩៥ លាននាក់នៅឆ្នាំ ២០៣០ ខណៈអ្នកអាចរកប្រាក់ចំណូលខ្ពស់បំផុតក៏កំពុងកើន

ឡើងផងដែរ។ ចំនួនមនុស្សដែលមានទ្រព្យសម្បត្តិសុទ្ធពី ១ លានដុល្លារ ទៅ ៣០លានដុល្លារនឹងកើនឡើង ៣២% ដល់ជិត ២៦ ០០០នាក់ នៅឆ្នាំ ២០២៥។ ទន្ទឹមនេះទីផ្សារផលិតផលប្រណិតនៅវៀតណាម ក៏ទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអឺរ៉ុប-វៀតណាម និងកិច្ចព្រមព្រៀងការពារការវិនិយោគក្នុងឆ្នាំ ២០១៩ ដែលបានដកចេញ ៩៩% នៃពន្ធគយទាំងអស់ និងកាត់បន្ថយរបាំងបទប្បញ្ញត្តិជាច្រើនផងដែរ។ *ដោយ ម៉ែន ខែមរៈ*

*[ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី២០ខែមករា ឆ្នាំ២០២២។]*

## កំណើនប្រាក់បញ្ញើនៅក្នុងធនាគារបានធ្លាក់ចុះនៅក្នុងឆ្នាំ២០២១



*ប្រភព៖ [Vietnam News] cafef.vn*

ប្រាក់បញ្ញើរបស់អតិថិជននៅក្នុងធនាគារទាំងអស់នៅក្នុងប្រទេសវៀតណាមកាលពីឆ្នាំ២០២១ កើនឡើងត្រឹមតែ ២,៦៣% ប៉ុណ្ណោះ គឺជាកំណើនទាបបំផុតដែលមិនធ្លាប់មានក្នុងអំលុងពេលជាច្រើនឆ្នាំកន្លងមកនេះ។ ទឹកប្រាក់បញ្ញើសរុបសម្រាប់ខែវិច្ឆិកាក្នុងឆ្នាំ២០២១ មានចំនួន ២២៦ប៊ីលានដុល្លារ ធ្លាក់ចុះទាបជាងខែតុលាចំនួន ២៣,៤ទ្រីលានដុង។

កំណើននៃប្រាក់បញ្ញើធ្លាក់ចុះដោយសារតែវិបត្តិកូវីដ ១៩ បានធ្វើឱ្យប្រាក់ចំណូលរបស់ពលរដ្ឋមួយចំនួនធំមានការធ្លាក់ចុះគួរឱ្យកត់សំគាល់។ ម្យ៉ាងវិញទៀត ដោយសារតែក្នុងអំលុងពេលរីករាលដាលកូវីដ ១៩ រដ្ឋាភិបាលបានដាក់ចេញវិធានការរក្សាគម្លាតសង្គមនៅតាមបណ្តាខេត្ត និងទីក្រុងនានា ដែលជាហេតុនាំឱ្យអតិថិជនមិនអាចធ្វើដំណើរទៅកាន់ធនាគារ ដើម្បីដាក់ប្រាក់បញ្ញើបាន។

ទន្ទឹមនឹងនេះ អ្នកជំនាញយល់ឃើញថា ដោយសារតែនៅក្នុងឆ្នាំ២០២១ អត្រាការប្រាក់បានធ្លាក់ចុះ នាំឱ្យអតិថិជនជាច្រើនដកប្រាក់សន្សំរបស់ពួកគេយកទៅបណ្តាក់ទុននៅក្នុងបណ្តាញវិនិយោគផ្សេងៗ។ កត្តានេះបានជម្រុញធនាគារជាច្រើនដំឡើងអត្រាការប្រាក់លើប្រាក់សន្សំ ដើម្បីទាក់ទាញអ្នកដាក់ប្រាក់បញ្ញើ។

ជាក់ស្តែងចាប់តាំងពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ធនាគារពាណិជ្ជ Saigon Commercial Joint Stock Bank (SCB) បានបង្កើនអត្រាការប្រាក់ពី ០,១% ទៅ ០,៣% នាំឱ្យអត្រាការប្រាក់របស់ធនាគារនេះកើនឡើងដល់ ៧,៦% ក្នុងមួយឆ្នាំ។ ប៉ុន្តែលក្ខខណ្ឌនៃការផ្តល់អត្រាការប្រាក់នេះ ផ្តល់ជូនសម្រាប់តែអតិថិជនដែលបានដាក់ប្រាក់បញ្ញើលើសពី ៥០០ប៊ីលានដុងនៅក្នុងអំលុងពេល ១៣ខែប៉ុណ្ណោះ។ សម្រាប់អតិថិជនដែលដាក់ប្រាក់បញ្ញើតិចក៏ទទួលបានអត្រាការប្រាក់ខ្ពស់ដែរ បើធៀបទៅនឹងធនាគារផ្សេងទៀត ពីចន្លោះពី ៧% ទៅ ៧,៣៥% ក្នុងមួយឆ្នាំ ក្នុងអំលុងពេល ១២ខែ ឬលើស ១២ខែ និងសម្រាប់រយៈពេល ១៨ខែ ផ្អែកទៅតាមចំនួនទឹកប្រាក់នៃប្រាក់សន្សំរបស់អតិថិជន។

បន្ទាប់ធនាគារពាណិជ្ជ Nam A Commercial Joint Stock Bank (NamABank) គឺជាធនាគារដែលបានផ្តល់អត្រាការប្រាក់សម្រាប់ប្រាក់កម្ចីខ្ពស់ជាងគេបន្ទាប់ពីធនាគារ SCB គឺ ៧,៤% ក្នុងមួយឆ្នាំសម្រាប់អតិថិជនដែលដាក់ប្រាក់បញ្ញើចាប់ពី ១៦ខែឡើងទៅ និងបានផ្តល់អត្រាការប្រាក់ ៧,២% សម្រាប់អតិថិ

ជនដែលបានដាក់ប្រាក់បញ្ញើចាប់ពី ១២ខែ ទៅ ១៥ខែ។

ក្រៅពីនោះនៅមានធនាគារធំៗផ្សេងទៀតដែលបានដំឡើងអត្រាការប្រាក់សម្រាប់ប្រាក់បញ្ញើមានដូចជា ៖ Vietnam Prosperity Commercial Joint Stock Bank (VPBank), Asia Commercial Joint Stock Bank (ACB), Sài Gòn Hà Nội Commercial Joint Stock Bank (SHB), Sài Gòn Thương Tín Commercial Joint Stock Bank (Sacombank) and Export Import Commercial Joint Stock Bank (Eximbank)៕

*ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ Vietnam News ចេញផ្សាយ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២*

## ដោយសារតែតម្លៃប្រេងឡើងថ្លៃ រដ្ឋាភិបាលជប៉ុនសម្រេចផ្តល់ឧបត្ថម្ភធនដល់អ្នកលក់ប្រេង




*ប្រភព៖ The Japan Times: BIOOMBERG*

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរបស់ជប៉ុនលោក Koichi Hagiuda បាននិយាយថា រដ្ឋាភិបាលជប៉ុននឹងផ្តល់ប្រាក់ឧបត្ថម្ភធនជាលើកដំបូងដល់ឧស្សាហកម្មប្រេងដើម្បីទប់ស្កាត់ការឡើងថ្លៃប្រេងនៅក្នុងអំលុងពេលថ្មីៗនេះ។

កាលពីថ្ងៃច័ន្ទ តម្លៃប្រេងលក់រាយនៅប្រទេសជប៉ុនគិតជាមធ្យមមានតម្លៃប្រហែលជា ១,៥ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយលីត្រ ឬ១៧០,២យ៉េន កើនឡើងខ្ពស់បំផុតក្នុងអំលុងពេល ១៣ឆ្នាំកន្លងមកនេះ លើសពីដានតម្លៃដែលបានកំណត់ត្រឹមតែ ១៧០យ៉េនប៉ុណ្ណោះ ក្នុងមួយលីត្រ។ ហេតុនេះទើបរដ្ឋាភិបាលដាក់ចេញគោលនយោបាយឧបត្ថម្ភធនជូនដល់អ្នកលក់ប្រេងបោះដុំ។

នៅក្រោមកម្មវិធីនេះ រដ្ឋាភិបាលជប៉ុននឹងផ្តល់ជូនប្រាក់ឧបត្ថម្ភធនចំនួន ៣,៤យ៉េន ក្នុងមួយលីត្រ ដល់អ្នកចែកចាយ និងអ្នកនាំចូលប្រេងចំនួន ២៩ក្រុមហ៊ុនក្នុងអំលុងពេលមួយសប្តាហ៍ ដើម្បីទប់ស្កាត់ការឡើងថ្លៃប្រេងសាំង ប្រេងម៉ាស៊ូត ប្រេងកាត និងប្រេងឥន្ធនះ។ ការផ្តល់ទឹកប្រាក់ឧបត្ថម្ភធននេះនឹងត្រូវអនុវត្តចាប់ពីថ្ងៃព្រហស្បតិ៍នេះតទៅ ដែលនឹងមានសុពលភាពរហូតដល់បំណាច់ខែមិនា ឆ្នាំ២០២២។ រដ្ឋាភិបាលជប៉ុនសម្រេចអនុម័តកញ្ចប់ថវិកាចំនួន ៨០ប៊ីលានយ៉េនសម្រាប់កម្មវិធីឧបត្ថម្ភធននេះរហូតដល់បំណាច់ខែមិនា។

ក្រោយពីអនុវត្តកម្មវិធីនេះមួយសប្តាហ៍ នៅថ្ងៃទី០៣ ខែមិនា រដ្ឋាភិបាលជប៉ុននឹងធ្វើការវាយតម្លៃទឹកប្រាក់ឧបត្ថម្ភធននេះជាថ្មីឡើងវិញម្តងទៀត ផ្អែកទៅតាមបម្រែបម្រួលតម្លៃប្រេងលក់រាយ។ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មបានលើកឡើងថា៖ តម្លៃប្រេងកើនឡើងដោយសារតែធនាគារកណ្តាលរបស់អាមេរិកយល់ថាផលប៉ះពាល់របស់កូវីដ១៩ បំលែងថ្មី Omicron មកលើសេដ្ឋកិច្ចនឹងមានរយៈពេលបណ្តោះអាសន្នប៉ុណ្ណោះ ខណៈដែលប្រទេសផលិតប្រេងមានការព្រួយបារម្ភលើការផ្គត់ផ្គង់ប្រេង និងមានមូលហេតុមួយទៀតគឺបណ្តាលមកពីភាពតានតឹងវិបត្តិយោធានៅអ៊ុយក្រែន។

ទោះជាយ៉ាងណាក៏ដោយ ការអន្តរាគមន៍របស់រដ្ឋាភិបាលជប៉ុនលើតម្លៃប្រេងទទួលរងនូវការរិះគន់មួយចំនួន។ មានមតិខ្លះបានលើកឡើងថា ការអន្តរាគមន៍របស់រដ្ឋា

ភិបាលលើករណីនេះមានភាពហួសហេតុនាំឱ្យខូចតម្លៃទីផ្សារ។ ចំណែកឯឧស្សាហកម្មប្រេងរបស់ជប៉ុនបានបន្ទោសថា ការឡើងថ្លៃប្រេងនៅប្រទេសជប៉ុនគឺបណ្តាលមកពីរដ្ឋាភិបាលជប៉ុនយកពន្ធលើប្រេងខ្ពស់ពេក។ ព្រោះបើយោងតាមរបាយការណ៍របស់ក្រសួងហិរញ្ញវត្ថុជប៉ុន តម្លៃប្រេងសាំងលក់រាយនៅជប៉ុនមួយលីត្រត្រូវជាប់ពន្ធដល់ទៅជាង ៥០% ដែលពីមុនពន្ធលើអ្នកប្រើប្រាស់ប្រេងសាំងមានទំហំត្រឹមតែ ១០% ប៉ុណ្ណោះ បើគិតត្រឹមត្រីមាសទី២ ក្នុងឆ្នាំ២០២០៕ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖The Japan Times ចេញផ្សាយ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២*

## ម៉ាឡេស៊ី មិនផ្តល់កូតាពិសេសបន្ថែមទៀតសម្រាប់ការជ្រើសរើសពលករបរទេស




*ដោយ ៖ AKP*

ប្រទេសម៉ាឡេស៊ី នឹងមិនផ្តល់កូតាពិសេសបន្ថែមទៀតសម្រាប់ការជ្រើសរើសពលករបរទេសនៅក្នុងប្រទេសរបស់ខ្លួនទេ។ ដើម្បីទទួលបានពលករបន្ថែម និយោជកត្រូវដាក់ពាក្យស្នើសុំមួយទៀត ទៅកាន់ក្រសួងធនធានមនុស្ស (KSM) ឬដាក់ពាក្យទៅកាន់ក្រសួងមហាផ្ទៃដើម្បីធ្វើការពិនិត្យឡើងវិញ។ រាល់ពាក្យស្នើសុំឥឡូវនេះត្រូវតែឆ្លងកាត់គណៈកម្មាធិការវាយតម្លៃរបស់ក្រសួងដើម្បីកំណត់ចំនួនពលករបរទេសដែលមានសិទ្ធិធ្វើការងារ ដោយអនុលោមតាមលក្ខខណ្ឌដែលបានកំណត់។ ប្រសិនបើប្រព័ន្ធកូតាមិនត្រូវបានអនុវត្ត ហើយការជ្រើសរើសពលករអាចធ្វើទៅបានដោយសេរីនោះ ពលករបរទេស នឹងចូលទៅក្នុងប្រទេសម៉ាឡេស៊ីដោយសាមញ្ញដោយមិនគោរពតាមលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ដែលនាំឱ្យមានបញ្ហាសុខុមាលភាពផ្សេងៗកើតឡើង។

កាលពីមុន និយោជកត្រូវដោះស្រាយតាមរយៈក្រសួងមហាផ្ទៃទៅលើការងាររបស់ពលករបរទេស ប៉ុន្តែបច្ចុប្បន្ននេះ រាល់បញ្ហាទាំងនេះអាចធ្វើឡើងតាមរយៈក្រសួងធនធានមនុស្ស(KSM) ដើម្បីធានាបាននូវការអនុលោមតាមគោលនយោបាយ និងនីតិវិធីសម្រាប់ការជ្រើសរើសពលករបរទេស៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ information.gov.kh ចេញផ្សាយថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២។*

## វៀតណាម នឹងមានតម្រូវការម្រេចពីកម្ពុជាច្រើន



*ដោយ ខេមបូឌាមីស(គ្រាប់ម្រេចហាល)*

វៀតណាម បច្ចុប្បន្ន គឺជាទីផ្សារម្រេចដ៏ធំរបស់កម្ពុជា ដោយទិញពីកម្ពុជាដើម្បីកែច្នៃ និងនាំចេញបន្តទៅប្រទេសទី៣។ បច្ចុប្បន្ន ខណៈដែលតម្រូវការទីផ្សារពីអន្តរជាតិមានកាន់តែច្រើន ប៉ុន្តែការដាំម្រេចនៅវៀតណាមនៅមានកម្រិត ដូច្នេះ វៀតណាមអាចនឹងត្រូវការនាំចូលម្រេចពីកម្ពុជាកាន់តែច្រើនបន្ថែមទៀត។

ប្រធានសមាគមម្រេចកំពត យល់ឃើញថា ទីផ្សារម្រេចនាពេលបច្ចុប្បន្ន កាន់តែប្រសើរ បើប្រៀបនឹងរយៈពេលប៉ុន្មានឆ្នាំមុន។

អ្នកដាំម្រេច នៅខេត្តត្បូងឃ្មុំ និងអ្នកដាំម្រេច ក្នុងខេត្តកំពត បានបង្ហាញនូវអារម្មណ៍សប្បាយរីករាយ ព្រោះតែតម្លៃម្រេចនាពេលនេះប្រសើរជាងឆ្នាំមុនៗ។ នៅដើមឆ្នាំ២០២២ ម្រេចនៅខេត្តត្បូងឃ្មុំ មានតម្លៃ ១ម៉ឺន៥ពាន់រៀល ក្នុងមួយគីឡូក្រាម បើប្រៀបនឹងឆ្នាំ២០២១

មានតម្លៃ ១ម៉ឺន២ពាន់រៀល ប៉ុណ្ណោះ ក្នុងមួយគីឡូក្រាម។

នៅក្នុងឆ្នាំ២០២១ កម្ពុជានាំចេញម្រេចសរុបជាង ២ម៉ឺន៨ពាន់តោន កើនឡើងដល់ទៅជាង ៤៥០% ក្នុងនោះ ការនាំចេញទៅកាន់ប្រទេសវៀតណាម មានក្នុងបរិមាណ ២ម៉ឺន៧ពាន់តោន មានប្រហែលជាង៩០% នៃការនាំចេញម្រេចសរុប។

រដ្ឋមន្ត្រីក្រសួងកសិកម្មកម្ពុជា ធ្លាប់បានអះអាងថា ប្រទេសវៀតណាមមួយរយៈចុងក្រោយនេះបានធ្វើផ្លាស់ប្តូរមុខដំណាំដាំដុះមួយចំនួន ដែលមិនទទួលបានប្រាក់ចំណូល ហើយមិនស្របនឹងការរីកចម្រើនខាងសេដ្ឋកិច្ចរបស់ប្រទេសមួយនេះ ដោយងាកទៅដាំដុះប្រភេទដំណាំយុទ្ធសាស្ត្រវិញ ដូចជាផ្លែឈើ សម្រាប់នាំចេញជាដើម។ ដូច្នេះហើយ ទើបវៀតណាមទិញម្រេចពីកម្ពុជាកាន់តែច្រើន ដើម្បីកែច្នៃនាំចេញបន្ត។ ប្រទេសវៀតណាម បាននិងកំពុងស្វែងរកមធ្យោបាយថ្មី ដើម្បីស្តារឧស្សាហកម្មម្រេចឡើងវិញ។ ប៉ុន្តែ បច្ចុប្បន្នប្រទេសវៀតណាម មិនទាន់មានវត្ថុធាតុដើមគ្រប់គ្រាន់នោះទេសម្រាប់កែច្នៃនាំចេញ ដូច្នេះ វៀតណាម កំពុងពិចារណានាំចូលម្រេចពីប្រទេសជិតខាង ពិសេសពីប្រទេសកម្ពុជាតែម្តង ដើម្បីធានាការផ្គត់ផ្គង់គ្រប់គ្រាន់សម្រាប់ដំណើរការក្នុងស្រុក ហើយវៀតណាមរំពឹងថា កម្ពុជា នឹងអាចជួយបំពេញតម្រូវការម្រេចដែលកំពុងខ្វះខាតនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី២៥ខែមករា ឆ្នាំ២០២២។*

## អតិផរណាក្នុងប្រទេសឡាវឈានឡើងដល់ ៥,៣ភាគរយក្នុងខែធ្នូ ឆ្នាំ២០២១



*ប្រភព៖ ក្រសួងព័ត៌មាន*

ការិយាល័យស្ថិតិឡាវ បានបង្ហាញថា អត្រាអតិផរណានៅក្នុងខែតុលាមានចំនួន ៤,៧២% ហើយក្នុងខែវិច្ឆិកាមានចំនួន ៥,០៤%។ នៅក្នុងខែធ្នូ អត្រាអតិផរណា មានខ្ពស់ជាងខែផ្សេងៗទៀតកាលពីក្នុងឆ្នាំ២០២១ ដោយឈានឡើងដល់ចំនួន ៥,៣ភាគរយ ដែលជះឥទ្ធិពលដោយផ្ទាល់ដល់ការចំណាយនៃការរស់នៅនៅក្នុងប្រទេស។

ការចំណាយលើការដឹកជញ្ជូនបានកើនឡើង ១២,៧%, តម្លៃសេវាកម្មសណ្ឋាគារ និងភោជនីយដ្ឋានកើនឡើង ៨,៣%, តម្លៃនៃការថែទាំសុខភាព និងឱសថកើនឡើង ៨,២%, តម្លៃទំនិញ និងសេវាកម្មកើនឡើង ៧,៩%, តម្លៃគ្រឿងស្រវឹង និងថ្នាំជក់ក៏បានកើនឡើង ៦,៨%, របស់ប្រើប្រាស់ចាំបាច់ដូចជា ទឹក អគ្គិសនី និងឧស្ម័នចម្អិនអាហារទាំងអស់បានកើនឡើង៥,៨%ដែរ។ សម្លៀកបំពាក់ និងស្បែកជើងបានកើនឡើង ៥,៤% ហើយតម្លៃគ្រឿងសង្ហារឹមបានកើនឡើង ៤,៩%។

អតិផរណាកាន់តែអាក្រក់ទៅៗដោយសារជំងឺរាតត្បាតកូវីដ-១៩ ការបិទព្រំដែនរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ពិភពលោក និងកង្វះផលិតកម្មក្នុងស្រុក។ ទំនិញរបស់ប្រទេសឡាវភាគច្រើនត្រូវបាននាំចូលដោយបានបង្កើតឱនភាពពាណិជ្ជកម្ម និងតម្រូវការរូបិយប័ណ្ណបរទេស (ប្រាក់បាតថៃ និងដុល្លារអាម៉េរិក) កំពុងកើនឡើង និងតម្លៃរូបិយប័ណ្ណក្នុងស្រុក មានការធ្លាក់ចុះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ក្រសួងព័ត៌មានចេញផ្សាយថ្ងៃទី២៥ខែមករាឆ្នាំ២០២២។*

## សេដ្ឋកិច្ចសកល

## រុស្ស៊ី ចង់ពង្រឹងទំនាក់ទំនងជាមួយប្រទេសអាស៊ាន




*ដោយ ៖ AKP*

ទិសដៅការទូតរបស់ប្រទេសរុស្ស៊ីនៅក្នុងឆ្នាំ២០២២ គឺមើលឃើញនូវអនាគតដ៏ល្អ ក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវភាពជាដៃគូឈ្នះ-ឈ្នះ ជាមួយបណ្ដាប្រទេសទាំងអស់ជាសមាជិកអាស៊ាន។ ប្រទេសរុស្ស៊ី នឹងផ្តោតទៅលើការបង្កើនសក្តានុពលនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យ សេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ នយោបាយ សន្តិសុខ និងបច្ចេកវិទ្យា ហើយសង្ឃឹមថា នឹងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសនៅអាស៊ានក្នុងវិស័យវប្បធម៌ សកម្មភាពមនុស្សធម៌ និងការបន្តសកម្មភាពទេសចរណ៍ឡើងវិញ បន្ទាប់ពីមានការរំខានរយៈពេលពីរឆ្នាំដោយសារផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩។ នៅក្នុងឆ្នាំ២០២២ ប្រទេសរុស្ស៊ីគ្រោងនឹងរៀបចំកិច្ចប្រជុំជាទៀងទាត់រវាងគណៈកម្មាធិការអន្តររដ្ឋាភិបាល កិច្ចពិគ្រោះយោបល់ថ្នាក់ក្រសួងការបរទេស និងកិច្ចប្រជុំកម្រិតខ្ពស់នានាជាមួយបណ្ដាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍។

រុស្ស៊ីគាំទ្រតួនាទីឈានមុខគេរបស់អាស៊ាន ក្នុងការស្វែងរកការគាំទ្រអន្តរជាតិ ប្រកបដោយភាពស្ថាបនាសម្រាប់មីយ៉ាន់ម៉ា។ ប្រទេសរុស្ស៊ី មានឆន្ទៈក្នុងការធ្វើការងារជាមួយដៃគូអាស៊ាន ក្នុងការផ្តល់ជំនួយមនុស្សធម៌ដល់ប្រទេសមីយ៉ាន់ម៉ា រួមទាំងការគាំទ្រក្នុងការប្រយុទ្ធប្រឆាំង នឹងជំងឺរាតត្បាតកូវីដ-១៩ ផងដែរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖information.gov.khVNAចេញផ្សាយថ្ងៃទី២៤ខែមករាឆ្នាំ ២០២២។*

## អាមេរិក និងអង់គ្លេស ផ្តើមកិច្ចពិភាក្សាដោះស្រាយជម្លោះពាណិជ្ជកម្មលើពន្ធដែកថែប និងអាលុយមីញ៉ូម



*ដោយ ៖ ខេមបូណូមីស*

អស់រយៈពេលជិត ៤ ឆ្នាំហើយ ទំនាក់ទំនងពាណិជ្ជកម្មដែកថែប និងអាលុយមីញ៉ូមរវាងមហាអំណាចអាមេរិក និងចក្រភពអង់គ្លេសមានភាពតានតឹង។ ថ្មីៗនេះភាគីទាំងពីរ បានព្រមព្រៀងគ្នាចរចា ដើម្បី ដោះស្រាយជម្លោះជុំវិញការដំឡើងពន្ធដាក់គ្នាលើដែកថែប និងអាលុយមីញ៉ូម ក៏ប៉ុន្តែមិនទាន់មានកាលបរិច្ឆេទដាក់លាក់ណាមួយសម្រាប់ការចរចានេះទេ។ ការពិភាក្សានេះត្រូវបានគេមើលឃើញថា អាចនឹងដោះស្រាយនូវបញ្ហាអំពីការអនុវត្តពន្ធរបស់សហរដ្ឋអាមេរិក លើលោហៈធាតុពីចក្រភពអង់គ្លេសផងដែរ។ អាមេរិក និងអង់គ្លេសបានប្ដេជ្ញាធ្វើការឆ្ពោះទៅរកការបញ្ចប់វិវាទឱ្យបានឆាប់រហ័ស ដែលធានាបាននូវលទ្ធផលជោគជ័យ នៃឧស្សាហកម្មដែកថែប និង អាលុយមីញ៉ូមនៅក្នុងទីផ្សាររបស់ប្រទេសទាំងពីរ។ ទន្ទឹមនេះ កិច្ចពិភាក្សានេះក៏នឹងផ្តោតលើបញ្ហាសងសឹកគ្នាលើផ្នែកពន្ធ ដែលចក្រអង់គ្លេសបានដាក់ពន្ធ ២៥% ទៅលើផលិតផលអាមេរិកមួយចំនួន រួមមាន ស្រាវីស្គី ម៉ូតូ ខោខូវប៊យពណ៌ខៀវ និង ថ្នាំជក់ផងដែរ។

ការនាំចេញស្រាវីស្គីប្រចាំឆ្នាំរបស់សហរដ្ឋអាមេរិក ទៅចក្រភពអង់គ្លេស បានធ្លាក់ចុះជាងពាក់កណ្ដាលចាប់តាំងពីឆ្នាំ២០១៨ ក្រោយពីរងការយកពន្ធច្រើនពីអង់គ្លេស។ ដោយឡែក អង់គ្លេសវិញ មានបំណងចង់ចរចាលើការនាំចេញដែកថែប និងអាលុយមីញ៉ូមទៅកាន់ទីអាមេរិកដោយឥតបង់ពន្ធ ដែលស្រដៀងនឹងអ្វីដែលរដ្ឋាភិបាលក្រុងវ៉ាស៊ីនតោនបានផ្ដល់ឱ្យសហភាពអឺរ៉ុបនៅថ្ងៃទី ១ ខែមករា កន្លងទៅនេះដែរ។ តែយ៉ាងណាមិញ ក្រុមហ៊ុនផលិតដែកថែបរបស់អាមេរិកបានព្រមានប្រឆាំងនឹងការចរចារបស់អង់គ្លេសនេះ រួមទាំងប្រឆាំងនឹងការចរចា ស្រដៀងគ្នាជាមួយប្រទេសជប៉ុនផងដែរ។

កាលពីខែ មីនា ឆ្នាំ ២០១៨ អតីត ប្រធានាធិបតីអាមេរិក លោក ដូ ណាល់ត្រាំ បានប្រកាសដំឡើងពន្ធលើលោហៈធាតុរបស់អង់គ្លេសមួយចំនួន ក្នុងនោះរួមមានពន្ធលើដែកថែប ២៥% និង អាលុយមីញ៉ូម ១០% ដែលនាំចូលទៅកាន់អាមេរិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២១ ខែមករា ឆ្នាំ២០២២។*

## ការតម្លើងអត្រាការប្រាក់របស់ធនាគារសហព័ន្ធអាមេរិក នឹងអាចធ្វើឱ្យវិបត្តិបំណុលសកលកាន់តែធ្ងន់ធ្ងរ




*ប្រភព៖ CNBC, រូបភាព៖ AFP*

យោងតាមរបាយការណ៍ថ្មីមួយរបស់យុទ្ធនាការទាមទារសេរីភាពពីបំណុលអយុត្តិធម៌ ( Jubilee Debt Campaign, JDC ) ក្នុងចក្រភពអង់គ្លេស បង្ហាញថា ការតម្លើងអត្រាការប្រាក់របស់ធនាគារសហព័ន្ធអាមេរិក និងធនាគារកណ្ដាលដ៏ទៃទៀត នឹងអាចបង្កឱ្យវិបត្តិបំណុលសកលកាន់តែមានស្ថានភាពអាក្រក់ឡើង ជាពិសេស ចំពោះប្រទេសកំពុងអភិវឌ្ឍ។ ក្នុងនោះដែរ របាយការណ៍នេះគូសបញ្ជាក់ថា ការទូទាត់បំណុលរបស់ប្រទេសកំពុងអភិវឌ្ឍ បានកើនឡើង ១២០% រវាងពីឆ្នាំ២០១០ ទៅឆ្នាំ២០២១ និងស្ថិតនៅកម្រិតខ្ពស់បំផុត បើគិតចាប់ពីឆ្នាំ២០០១មក។

គួរបញ្ជាក់ដែរថា ការកើនឡើងយ៉ាងខ្លាំងនៃការទូទាត់បំណុលនេះ បានរាំងស្ទះដល់ការងើបឡើងវិញរបស់សេដ្ឋកិច្ច ស្របពេលដែលការកើនឡើងនៃអត្រាការប្រាក់សកល និងសហរដ្ឋអាមេរិក នឹងដាក់បន្ទុកបន្ថែមទៅដល់ប្រទេសដែលមានចំណូលទាបជាច្រើន ដែលមានបំណុលជាប្រាក់ដុល្លារ។

ទន្ទឹមនេះដែរ លោកស្រី Kristalina Georgieva នាយកគ្រប់គ្រងមូលនិធិរូបិយវត្ថុអន្តរជាតិ ( IMF ) លើកឡើងថា ការតម្លើងអត្រាការប្រាក់របស់សហរដ្ឋអាមេរិក នឹងបង្កើតឱ្យមានភាពលំបាកដល់ប្រទេសមួយចំនួនដែលការងើបឡើងវិញនៃសេដ្ឋកិច្ចកំពុងមានភាពទន់ខ្សោយស្រាប់។ ចំណែកឯ លោក Heidi Chow នាយកប្រតិបត្តិនៃយុទ្ធនាការទាមទារសេរីភាពពីបំណុលអយុត្តិធម៌ ( JDC ) បានគូសបញ្ជាក់ថា ប្រទេសមានចំណូលទាប បានបន្តទទួលរងផលប៉ះពាល់ពីវិបត្តិបំណុល និងមិនមានធនធានចាំបាច់គ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាអាកាសធាតុបន្ទាន់និងផលប៉ះពាល់ពីវិបត្តិជំងឺរាតត្បាត ខណៈការកើនឡើងអត្រាការប្រាក់ នឹងគំរាមកំហែងឱ្យប្រទេសទាំងនោះ ជំពាក់បំណុលកាន់តែច្រើន។

យោងតាមទិន្នន័យបំណុលរបស់ JDC បង្ហាញថា ប្រទេសចំនួន ៥៤ កំពុងជួបប្រទះនឹងវិបត្តិបំណុល ហើយការទូទាត់បំណុល បានរាំងស្ទះដល់សមត្ថភាពរបស់រដ្ឋាភិ-បាលក្នុងការធានារក្សានូវសិទ្ធិសង្គម និងសេដ្ឋកិច្ចរបស់

ប្រជាពលរដ្ឋ។ ជាក់ស្តែង ការទូទាត់បំណុលខាងក្រៅទាំងអស់នៃប្រទេសមានចំណូលទាប និងមធ្យម ក្នុងនោះ ៤៧%ទៅកាន់ម្ចាស់បំណុលឯកជន ២៧%ទៅកាន់ស្ថាប័នពហុភាគី ១២%ទៅកាន់ចិន និង១៤%ទៅកាន់រដ្ឋាភិបាលប្រទេសដ៏ទៃទៀត។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ CNBC ចេញផ្សាយ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២*

## សេដ្ឋកិច្ចប្រទេសឈូងសមុទ្រ នឹងមានកំណើនលឿននៅឆ្នាំ២០២២



*ប្រភព៖ Newsbreak ២០២១*

យោងតាមការស្រង់មតិសេដ្ឋវិទូរបស់ Reuters បានបង្ហាញថា សេដ្ឋកិច្ចប្រទេសចំនួន៦ ដែលជាសមាជិកនៃក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការឈូងសមុទ្រ (អារ៉ាប៊ីសាអូឌីត គុយវ៉ែត អារ៉ាប់រួម កាតា អូម៉ង់ និងបារ៉ែន) មានការរីកលូតលាស់យ៉ាងលឿន ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ គួរបញ្ជាក់ថា ការស្រង់មតិលើសេដ្ឋវិទូចំនួន ២៥រូប បានព្យាករថា សម្រាប់ឆ្នាំ២០២២ សេដ្ឋកិច្ចប្រទេសឈូងសមុទ្រ នឹងមានកំណើនលឿនជាងការរំពឹងទុកកាលពី៣ខែមុន។ នេះដោយសារតែ តម្លៃប្រេងឆៅ ដែលបានកើនឡើងទៅចំណុចខ្ពស់បំផុត គិតចាប់ពីឆ្នាំ២០១៤មក បង្កមកពីការកើនឡើងនៃភាពតានតឹងនយោបាយសកលរវាងប្រទេសផលិតចម្បង ដែលរួមមាន៖ រុស្ស៊ី និងអារ៉ាប់រួម។

សេដ្ឋកិច្ចអារ៉ាប៊ីសាអូឌីតឆ្នាំ២០២២ ត្រូវបានព្យាករ មានកំណើនខ្ពស់ជាងគេ ក្នុងអត្រា ៥,៧% បន្ទាប់មក ប្រទេសគុយវ៉ែត ៥,៣% និងអារ៉ាប់រួម ៤,៨%។ ចំណែកឯប្រទេស ៣ទៀត មានកំណើនក្នុងរង្វង់ ៣% ទៅ ៤%។

ខណៈដែរ សេដ្ឋកិច្ចសកល កំពុងដោះស្រាយបញ្ហាអតិផរណាដែលកំពុងកើតមានឡើង ចំពោះស្ថានភាពអតិផរណាក្នុងតំបន់នេះវិញ មានកម្រិតទាប ដោយអត្រានេះ ត្រូវបានរំពឹងថា ស្ថិតនៅចន្លោះ ២% ទៅ២,៨%។ លោក Ralf Wiegert ប្រធានក្រុមសេដ្ឋកិច្ចតំបន់មជ្ឈិមបូព៌ានិងអាហ្វ្រិកខាងជើងនៃ IHS Markit លើកឡើងថា ការធ្លាក់ចុះនៃតម្លៃប្រេងគឺជាហានិភ័យធំបំផុត ចំពោះទស្សនវិស័យកំណើនសេដ្ឋកិច្ចនៃប្រទេសសមាជិកក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការឈូងសមុទ្រនេះ។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Hellenic Shipping News Worldwide ចេញផ្សាយ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២*

## លោក ចូ បៃឌិន៖ មិនទាន់ដល់ពេលដែលត្រូវដកនាំងពន្ធគយពីទំនិញចិនឡើយ



*ដោយ ខេមបូណ្ណមីស*

កន្លងមក មានក្រុមហ៊ុនអាមេរិកជាច្រើនត្អូញត្អែរពីផលវិបាក ក្នុងការដោះដូរទំនិញជាមួយក្រុមហ៊ុនចិន ដោយសារតែបញ្ហារនាំងពន្ធគយនេះ។ ក្រុមហ៊ុនបានស្នើទៅរដ្ឋបាលក្រុងវ៉ាស៊ីនតោន ឱ្យទម្លាក់ចោលវិញនូវអត្រាពន្ធគយចំនួន ២៥% ដែលបានដាក់លើទំនិញរបស់ប្រទេសចិន កាលពីជំនាន់លោកដូណាល់ត្រាំនៅជាប្រធានាធិបតី។

ប្រធានាធិបតីអាមេរិកបច្ចុប្បន្ន បាននិយាយថា វាលឿនពេកហើយដែលសហរដ្ឋអាមេរិក និងដករនាំងពន្ធគយលើទំនិញមកពីប្រទេសចិនវិញ។

និយាយបែបនេះ គឺចង់សំដៅដល់ជំហររបស់ក្រុងប៉េកាំង ក្នុងការសម្រេចឱ្យ បានជាលទ្ធផល ស្របទៅនឹងកិច្ចព្រមព្រៀងដោះស្រាយជម្លោះពាណិជ្ជកម្មដំណាក់កាលទី១ រវាងចិននិងអាមេរិក ដែលបានចុះហត្ថលេខាកន្លងមកមក។ អាមេរិកកំពុងរង់ចាំមើលជំហររបស់ប្រទេសចិនជាមុនសិន ថាចិនអាចសម្រេចបានតាមការព្រមព្រៀងនៅពេលណា ប៉ុន្តែសម្រាប់អាមេរិក គឺមិនទាន់ដល់ពេលត្រូវដកនាំងពន្ធគយនៅឡើយ។ ចិនមិនបានអនុវត្តពេញលេញទៅតាមកិច្ចព្រមព្រៀងនេះទេ ដែលតម្រូវឱ្យ ប៉េកាំងបញ្ជាទិញទំនិញប្រមាណ២០០ពាន់លានដុល្លារបន្ថែមទៀតពីសហរដ្ឋអាមេរិក សម្រាប់ឆ្នាំ ២០២០ និង២០២១។ ក្នុងនោះគិតត្រឹមខែវិច្ឆិកាឆ្នាំ ២០២១ ចិនសម្រេចតាមកិច្ចព្រមព្រៀង ដោយបញ្ជាទិញទំនិញអាមេរិក បានតែ៦០%នៃផែនការប៉ុណ្ណោះ។ ទោះបីជាបែបនេះក្តី ក៏តំណាងពាណិជ្ជកម្មរបស់អាមេរិកកំពុងធ្វើការចរចាដើម្បីរកច្រកចេញក្នុងបញ្ហានៃទំនាក់ទំនងពាណិជ្ជកម្ម រវាងអាមេរិកជាមួយប្រទេសចិននេះ។

គួរកត់សម្គាល់ថា ទោះបីជារនាំងពន្ធគយក្នុងការដោះដូរទំនិញរវាងមហាអំណាចទាំងពីរមិនទាន់ត្រូវបានដកចេញវិញក្តី ប៉ុន្តែទំហំពាណិជ្ជកម្មរវាងភាគីទាំងពីរបន្តកើនឡើងឥតឈប់ឈរ។ ជាក់ស្តែង នៅពេញមួយឆ្នាំ ២០២១ ទំហំពាណិជ្ជកម្មរវាងអាមេរិក និងចិនមានទឹកប្រាក់សរុបជាង ៧០០ពាន់លានដុល្លារអាមេរិក កើនឡើងជិត៣០% បើធៀបនឹងឆ្នាំ ២០២០៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី២១ ខែមករា ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី៣១ ខែមករា ឆ្នាំ២០២២

- ឱនភាពពាណិជ្ជកម្មរបស់ប្រទេសទួរគី ក្នុងខែវិច្ឆិកា ឆ្នាំ 2021 ដែលជាគម្លាតដ៏ធំបំផុតចាប់តាំងពីខែសីហា ឆ្នាំ 2020
- កំណើន ប្រាក់ចំណូលពីទេសចរណ៍នៅក្នុងប្រទេសទួរគី នៅក្នុងត្រីមាសទី 3 ឆ្នាំ 2021

ថ្ងៃអង្គារ ទី០១ ខែកុម្ភៈ ឆ្នាំ២០២២

- ម៉ិកស៊ិក បានកត់ត្រាឱនភាពថវិការបស់រដ្ឋាភិបាលក្នុងខែវិច្ឆិកា ឆ្នាំ 2021
- កំណើនអត្រានីកម្មភាព របស់ប្រទេសជប៉ុនក្នុងខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃពុធ ទី០២ ខែកុម្ភៈ ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្ម ប្រទេសប្រេស៊ីល ក្នុងខែធ្នូ ឆ្នាំ 2021
- ឱនភាពថវិការដ្ឋាភិបាល របស់ប្រទេសបារាំងក្នុងខែមករា ដល់ខែវិច្ឆិកាឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី០៣ ខែកុម្ភៈ ឆ្នាំ២០២២

- កំណើនចំណូលពន្ធនៅក្នុងប្រទេសអាហ្សង់ទីនក្នុងខែធ្នូ ឆ្នាំ 2021
- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលីបានធ្លាក់ចុះ ខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃសុក្រ ទី០៤ ខែកុម្ភៈ ឆ្នាំ២០២២

- សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកូរ៉េខាងត្បូងបានកើនឡើង 0.20% នៅក្នុងខែធ្នូ ឆ្នាំ 2021 ធៀបនឹងខែមុន
- អត្រានីកម្មភាពនៅប្រទេសកាណាដា បានធ្លាក់ចុះដល់កម្រិតទាប ក្នុងខែធ្នូ ឆ្នាំ 2021៕